



**Asian International Justice Initiative (AIJI), a project of East-West Center and the WSD HANDA Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**


# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ៧៩

បន្ទាប់ពីសវនាការអស់រយៈពេលចំនួន២៧៤ថ្ងៃ ដោយបានស្តាប់សក្ខីកម្មសាក្សីចំនួន១១៤នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងសាក្សីជំនាញចំនួន៨នាក់រួចមក សប្តាហ៍នេះត្រូវបានកត់សម្គាល់ថាជាសប្តាហ៍ចុងក្រោយនៃសវនាការលើកស្តុតាងក្នុងសំណុំរឿង០០២ វគ្គ២។[1] អង្គជំនុំជម្រះសាលាដំបូង បានធ្វើសវនាការចំនួនបីថ្ងៃក្នុងសប្តាហ៍នេះ ដើម្បីស្តាប់សក្ខីកម្មរបស់សាក្សីចុងក្រោយ និងធ្វើការពិភាក្សាអំពីបញ្ហានានា

[1] អង្គជំនុំជម្រះ បានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះអាចនឹងបើកកិច្ចដំណើរការនីតិវិធីសវនាការឡើងវិញ នៅមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ខាងមុខនេះ លុះត្រា អង្គជំនុំជម្រះអាចមានលទ្ធភាពក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីដែលមានអត្តលេខ **2-TCW-946** តាមរយៈប្រព័ន្ធសោតទស្សន៍ពីប្រទេសអាឡឺម៉ង់បាន ក៏ប៉ុន្តែជាការកត់សម្គាល់ថា អង្គជំនុំជម្រះមិនមានបំណងក្នុងការស្តាប់សក្ខីកម្មសាក្សីណាមួយបន្តទៅទៀតឡើយ។ ចំពោះគ្រប់សេចក្តីសម្រេច ឬសេចក្តីសម្អាងហេតុជាលាយលក្ខណ៍អក្សរទាំងអស់ដែលមិនទាន់បានធ្វើរួចរាល់ នឹងត្រូវបានផ្សព្វផ្សាយដោយអង្គជំនុំជម្រះសាលាដំបូងក្នុងពេលឆាប់ៗតាមដែលអាចធ្វើទៅបាន។ អង្គជំនុំជម្រះសាលាដំបូង ក៏បានកត់សម្គាល់ផងដែរថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានប្តឹងជំទាស់ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីបទចោទប្រកាន់នៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបពាហ៍ពិពាហ៍ដោយបង្ខំ នៅបន្តនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅឡើយ ទោះបីជាយ៉ាងនេះក្តី ជាការកត់សម្គាល់ថា ដោយមិនគិតពីលទ្ធផលខាងលើនេះ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានថ្លែងថា ពួកគេនឹងមិនស្នើសុំឲ្យមានការកោះហៅសាក្សីបន្ថែមណាមួយឡើយជុំវិញបញ្ហានេះ។ ជាងនេះទៅទៀត អ្នកឃ្លាំមើលសវនាការបានកត់សម្គាល់ថា លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានប្រកាសរយៈពេលសរុបនៃថ្ងៃធ្វើសវនាការចំនួន២៧៤ថ្ងៃ ចំពោះសំណុំរឿង០០២ វគ្គ២នេះ ក៏ប៉ុន្តែរបាយការណ៍របស់យើងខ្ញុំបានយោងសម្អាងលើចំនួនត្រឹមតែ២៧៣ថ្ងៃប៉ុណ្ណោះ។ ប្រការនេះ ត្រូវបានសន្និដ្ឋានថា តុលាការបានរាប់បញ្ចូលថ្ងៃធ្វើសវនាការបឋមចំនួនមួយថ្ងៃផងដែរ ដែលចំនួនមួយថ្ងៃនេះមិនត្រូវបានរាប់បញ្ចូលក្នុងរបាយណ៍របស់យើងខ្ញុំនោះឡើយ។

ពាក់ព័ន្ធនឹងការបិទបញ្ចប់សវនាការជំនុំជម្រះក្តីនេះផងដែរ។ នៅថ្ងៃចន្ទ សាក្សីជំនាញអ្នកស្រី **ហ៊ីន សុធានី** ដែលជាអតីតបុគ្គលិកនៃការិយាល័យសហចៅក្រមស៊ើបសួរ បានមកផ្តល់សក្ខីកម្មអំពីការងាររបស់អ្នកស្រីក្នុងការចងក្រងបញ្ជីអ្នកទោសចំនួន ១៥,១០១ នាក់ ដែលបានចូលមកមន្ទីរសន្តិសុខ ស-២១ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅថ្ងៃអង្គារ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មដែលនៅសេសសល់របស់លោក **វឿន វុទ្ធី** ដែលជាបុរាណវត្ថុវិទូ ធ្លាប់បានផ្តល់សក្ខីកម្មរបស់គាត់ក្នុងឋានៈជាសាក្សីជំនាញកាលពីខែធ្នូ ឆ្នាំ២០១៦។ បន្ទាប់ពីនេះមកក្រុមមេធាវីការពារក្តីឲ្យលោក **ខៀវ សំផន** ត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍តបរបស់ការិយាល័យសហព្រះរាជអាជ្ញាទៅលើការដាក់បង្ហាញឯកសារគន្លឹះរបស់ខ្លួនកាលពីសប្តាហ៍មុន។ ដោយសារតែការផ្តល់សក្ខីកម្មតាមរយៈប្រព័ន្ធសោតទស្សន៍របស់សាក្សីដែលមានអត្តលេខ **2-TCW-946** ពីប្រទេសអាឡឺម៉ង់មិនអាចរៀបចំទៅបាន នៅពេលព្រឹកថ្ងៃពុធ ភាគីទាំងអស់បានធ្វើសារណាផ្ទាល់មាត់ ពាក់ព័ន្ធនឹងរបៀបដំណើរការនៃបទចោទប្រកាន់ដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ផងដែរនេះ។ បន្ទាប់ពីមានការពិភាក្សាខ្លីមួយស្តីពីបញ្ហាខ្វះខាតធនធានក្នុងក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះបានផ្អាកកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃពុធពេលព្រឹក ដោយបានប្រកាសថា គ្មានសាក្សីដែលនឹងត្រូវបានរំពឹងទុកថា នឹងត្រូវកោះហៅក្នុងសំណុំរឿង ០០២ វគ្គ២នេះ បន្តទៅទៀតឡើយ។ ចាប់ពីពេលនេះតទៅ ភាគីមានរយៈពេលចំនួនបីខែ ដើម្បីរៀបចំសារណាសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល ហើយសេចក្តីថ្លែងការណ៍សន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលនឹងគ្រោងធ្វើឡើងនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ។[2]

[2] លោកប្រធានអង្គជំនុំជម្រះសាលាដំបូង បានប្រកាសថា សារណាសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល ត្រូវដាក់ឯកសារនៅថ្ងៃកំណត់ ទី២៤ ខែមេសា ឆ្នាំ២០១៧ ខាងមុខនេះ ជាភាសាណាមួយដែលប្រើប្រាស់នៅ អ.វ.ត.ក ហើយបានកត់សម្គាល់ថា ពុំមានសារណាឆ្លើបតបជាលាយលក្ខណ៍ណាមួយ នឹងត្រូវអនុញ្ញាតទទួលយកនោះឡើយ។ ចំពោះការកម្រិតចំនួនទំព័រនៃសារណាសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោលត្រូវបានកំណត់ដូចតទៅ៖ ការិយាល័យសហព្រះរាជអាជ្ញា មិនត្រូវឲ្យលើពី៨០០ទំព័រ ហើយទាំងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីទាំងពីរ នឹងទទួលបានចំនួន៥៥០ទំព័រ ក្នុងក្រុមនីមួយៗ។ ចំពោះការទាមទារសំណងចុងក្រោយបង្អស់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី នឹងដាក់ថ្ងៃកំណត់ ទី២២ ខែឧសភា ឆ្នាំ២០១៧ ខាងមុខនេះ។ ចំពោះថិរវេលានៃការធ្វើសេចក្តីថ្លៃការណ៍សន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល ត្រូវបានកំណត់ដូចតទៅ៖ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានថិរវេលាចំនួនមួយថ្ងៃ ការិយាល័យសហព្រះរាជអាជ្ញាមានចំនួនបីថ្ងៃ និងក្រុមមេធាវីការពារក្តីទាំងពីរមានចំនួនពីរថ្ងៃក្នុងក្រុមនីមួយៗ។ ហើយថិរវេលាមួយថ្ងៃ នឹងគ្រោងធ្វើសម្រាប់ការឆ្លើយតបគ្នាទៅវិញទៅមក ហើយថិរវេលាចំនួន ៤ម៉ោង នឹងគ្រោងធ្វើសម្រាប់ការផ្តល់សេចក្តីថ្លែងការណ៍ចុងក្រោយរបស់ជនជាប់ចោទទាំងពីរ ប្រសិនបើជនជាប់ជនជ្រើសរើសការប្រើប្រាស់សិទ្ធិរបស់ពួកគេ។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ អាលីស៊ុន ហេនឌ្រិក (Allison Hendriks), អាមេនដា ហុញ (Amanda Huynh), ខេតលីន កាហ្វហ្រៀ (Caitlin McCaffrie), តាន់ ស៊ីវុត្ថា, តាយ លីណា, ធី លីលី និង ភីនីឡូភី វ៉ាន់ធូល (Penelope Van Tuyl) ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និងការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោង ផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌អន្តរជាតិ (The WSD HANDA Center) ដែលកាលពីមុនត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានាក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University